ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៤/១៣០៩ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ ស្តីពីគោរមងារឧកញ៉ា
- យោងតាមសំណូមពរចាំបាច់នៃការងារ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់ ក្នុងគោលបំណងដើម្បីជានាឱ្យមានឯកសណ្ឋានភាព ការលើកទឹកចិត្ត និងការពង្រឹងការទទួលខុសត្រូវក្នុងការអនុវត្តការងារផ្នែកសង្គមកិច្ច ការលើកតម្កើងកិត្តិយស សីលធម៌ គុណតម្លៃ និងសេចក្តីថ្លៃថ្នូនៃគោរមងារឧកញ៉ា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគោរមវន្តតាមលំដាប់ថ្នាក់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**មាត្រា៣ .-**

ឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់ មាន២ប្រភេទ ដូចខាងក្រោម៖

១- ឯកសណ្ឋានផ្លូវការប្រភេទ១។

២- ឯកសណ្ឋានផ្លូវការប្រភេទ២។

### ផ្នែកទី១
### ឯកសណ្ឋានផ្លូវការប្រភេទ១

**មាត្រា៤ .-**

ឯកសណ្ឋានផ្លូវការប្រភេទ១ រួមមានឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់។

**មាត្រា៥ .-**

ឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្ត ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ឯកសណ្ឋានគោរមវន្តបុរស**

**ក- អាវ៖**

- អាវកុត កតាំង ដៃវែង ពណ៌កាកអំពៅស្រាល ឆែកខ្នងខាងក្រោមទាំងសងខាង មានឡេវមុខពណ៌មាសផុសចំនួន៥គ្រាប់ មានហោប៉ៅកាត់លើទ្រូងខាងឆ្វេងចំនួន១ និងហោប៉ៅប៉ះមានគម្របរាងស្លឹកពោធិ៍ខាងក្រោមសងខាង បោះរន្ធដាក់ឡេវពណ៌មាសផុសចំកណ្តាល
- ចុងដៃអាវឆែកទាំងសងខាង មានឡេវចំនួន៤គ្រាប់ ត្រង់ជួរគ្នា
- នៅលើស្មាអាវមានខ្សែរន្ធសងខាងធ្វើពីក្រណាត់ ដែលនៅម្ខាងៗមានរន្ធចំនួន២ សម្រាប់បំពាក់សក្តិលើស្មា។

**ខ- ខោ៖**

- ខោជើងវែងត្រង់ ពណ៌កាកអំពៅស្រាល
- ដេរច្នេះបង្កប់ ចង្កេះត ក្បាលខោវែងស្រួចប្រវែង ៥,៥សង់ទីម៉ែត្រ ជីបភ្លីខាងមុខម្ខាងមួយ និងមានហោប៉ៅចំនួន៣
- ហោប៉ៅចំហៀង២ មានមាត់បញ្ឆិត
- ហោប៉ៅកាត់ខាងក្រោយ១ នៅផ្នែកខាងស្តាំដេរបង្កប់មិនមានគម្រប។

**គ- ស្បែកជើងនិងស្រោមជើង៖**

- ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ កែងកម្ពស់ ៣សង់ទីម៉ែត្រឬកែងរាបស្មើ
- ស្រោមជើងពាក់កណ្តាលស្មងជើង ពណ៌ខ្មៅ។

គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្តបុរស ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។



៩៩

## ២- ឯកសណ្ឋានគោរមវន្តនារី

### ក- អាវ៖

- អាវកបើក ដៃវែង ពណ៌កាកអំពៅស្រាល ផ្នែកខ្នងខាងក្រោមមួយចំកណ្ដាល មានជីបរាងខ្នង មកក្រោមតាមលក្ខណៈអាវនារី មានឡេវមុខពណ៌មាសផុសចំនួន៥គ្រាប់ និងមានហោប៉ៅ ខាងមុខដេរបង្កប់ចំនួន២ នៅខាងក្រោមខិតចំហៀងចំចង្កេះទាំងសងខាង ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ខាងក្រោម ចោះរន្ធដាក់ឡេវពណ៌មាសផុសចំកណ្ដាល
- នៅចុងដៃអាវផ្នែកទាំងសងខាង មានឡេវចំនួន៣គ្រាប់ ត្រង់ជួរគ្នា
- នៅលើស្មាអាវមានខ្សែរន្ធសងខាងធ្វើពីក្រណាត់ ដែលនៅម្ខាងៗមានរន្ធចំនួន២ សម្រាប់ បំពាក់សក្តិលើស្មា។

### ខ- សំពត់បត់៖

- សំពត់បត់ ពណ៌កាកអំពៅស្រាល
- សម្រុងត្រឹមភ្នែកគោរ។

### គ- ស្បែកជើង និងស្រោមជើង៖

- ស្បែកជើងកែងចោត កខ្លី ស្បែកពណ៌ខ្មៅ កែងកម្ពស់ ៥សង់ទីម៉ែត្រ ឬកែងរាបស្មើ
- ស្រោមជើងកខ្លី ពណ៌ខ្មៅ។

គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្តនារី ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

## មាត្រា៦ .-

សញ្ញាសក្តិគោរមវន្តតាមលំដាប់ថ្នាក់សម្រាប់ពាក់លើស្មាទាំងសងខាងនៃឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ដូចខាងក្រោម៖

### ១- សញ្ញាសក្តិលោកអ្នកឧកញ៉ា៖

- មានទំហំ ៦សង់ទីម៉ែត្រ គុណនឹង ១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាស ព័ទ្ធជុំវិញសក្តិ ដោយផ្ទៃពណ៌ជីលែង
- មានរូបព្រះរាជសង្ហារមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់រង្វង់បង្កប់ដោយស្រះ(ឱ) ពេញតួ មានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាស ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាសរាងជាស្លឹកពោធិ៍ចំនួន៣គ្រាប់ នៅចំកណ្ដាលផ្ដើមចេញ ពីទំហំតូច មធ្យម និងធំ បន្តពីរូបព្រះរាជសង្ហារ
- នៅពីក្រោមគ្រាប់រង្វង់ទំហំធំមានសរសេរអក្សរថា លោកអ្នកឧកញ៉ា ពណ៌មាស ទ្រពីក្រោមដោយ ក្បាច់ភ្ញីទេសពណ៌មាសសម្រាប់សម្គាល់គោរមងារលោកអ្នកឧកញ៉ា។

### ២- សញ្ញាសក្តិអ្នកឧកញ៉ា៖

- មានទំហំ ៦សង់ទីម៉ែត្រ គុណនឹង ១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាស ព័ទ្ធជុំវិញសក្តិ ដោយផ្ទៃពណ៌បៃតង
- មានរូបព្រះរាជសង្ហារមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់រង្វង់បង្កប់ដោយស្រះ(ឱ) ពេញតួ មានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាស ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាសរាងជាស្លឹកពោធិ៍ចំនួន២គ្រាប់ នៅចំកណ្ដាលផ្ដើមចេញពី ទំហំតូចនិងធំ បន្តពីរូបព្រះរាជសង្ហារ



ᴉᴉ

- នៅពីក្រោមគ្រាប់រង្វង់ទំហំធំមានសរសេរអក្សរថា អ្នកឧកញ៉ា ពណ៌មាស ទ្រពីក្រោមដោយក្បាច់ភ្ញីទេសពណ៌មាសសម្រាប់សម្គាល់គោរមងារអ្នកឧកញ៉ា។

**៣- សញ្ញាសក្តិឧកញ៉ា៖**

- មានទំហំ ៦សង់ទីម៉ែត្រ គុណនឹង ១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញសក្តិ ដោយផ្ទៃពណ៌ខៀវចាស់
- មានរូបព្រះរាជសង្ហារមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់រង្វង់បង្កប់ដោយស្រៈ(ឱ) ពេញតួ មានក្បាលស្រៈជារូបក្បាលហង្ស ហើយតួស្រៈពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាសរាងជាស្លឹកពោធិ៍ចំនួន១គ្រាប់ នៅចំកណ្តាលបន្តពីរូបព្រះរាជសង្ហារ
- នៅពីក្រោមគ្រាប់រង្វង់មានសរសេរអក្សរថា ឧកញ៉ា ពណ៌មាស ទ្រពីក្រោមដោយក្បាច់ភ្ញីទេសពណ៌មាសសម្រាប់សម្គាល់គោរមងារឧកញ៉ា។

គំរូសញ្ញាសក្តិគោរមងារតាមលំដាប់ថ្នាក់សម្រាប់ពាក់លើស្មាទាំងសងខាងនៃឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

សញ្ញាសម្គាល់គោរមងារតាមលំដាប់ថ្នាក់នៃឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- សញ្ញាសម្គាល់ចុងកអាវ**

សញ្ញាសម្គាល់ចុងកអាវ កតាំងសម្រាប់បុរស និងចុងកអាវ កបើកសម្រាប់នារី មាននិមិត្តសញ្ញាសម្គាល់ដែលមានរំលេចចេញជាស្រៈ(ឱ)ពេញតួ មានក្បាលស្រៈជារូបក្បាលហង្ស ហើយតួស្រៈពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាសរាងជាស្លឹកពោធិ៍ទំហំខ្នាត ២,៦សង់ទីម៉ែត្រ គុណនឹង ៣,៥សង់ទីម៉ែត្រ កម្រាស់ ០,៣សង់ទីម៉ែត្រ។

**២- សញ្ញាសម្គាល់គ្រាប់ឡេវ**

គ្រាប់ឡេវមានរាងជារង្វង់មានស្រៈ(ឱ)ពេញតួនៅចំកណ្តាល ដែលមានក្បាលស្រៈជារូបក្បាលហង្ស ហើយតួស្រៈពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសផុសនៅចំកណ្តាលផ្ទៃរង្វង់ឡេវពណ៌មាស។ គ្រាប់ឡេវត្រូវបានបែងចែកជា២ខ្នាត ដែលមានទំហំអង្កត់ផ្ចិតដូចខាងក្រោម៖

- គ្រាប់ឡេវតូច ទំហំ ១,៥សង់ទីម៉ែត្រ កម្រាស់ ០,១សង់ទីម៉ែត្រ សម្រាប់ចុងដៃអាវ បញ្ឈរជាជួរត្រង់គ្នាចំនួន៤គ្រាប់ សម្រាប់គោរមងារបុរស និងចំនួន៣គ្រាប់ សម្រាប់គោរមងារនារី
- គ្រាប់ឡេវធំ ទំហំ ២សង់ទីម៉ែត្រ កម្រាស់ ០,២សង់ទីម៉ែត្រ សម្រាប់ឡេវមុខ បញ្ឈរជាជួរត្រង់គ្នាចំនួន៥គ្រាប់ និងគម្របហោប៉ៅចំនួន២គ្រាប់ សម្រាប់គោរមងារបុរសនិងនារី។

គំរូសញ្ញាសម្គាល់គោរមងារតាមលំដាប់ថ្នាក់នៃឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## ឯកសណ្ឋានផ្លូវការប្រភេទ២

**មាត្រា៨ .-**

ឯកសណ្ឋានផ្លូវការប្រភេទ២ រួមមានឯកសណ្ឋាន និងសញ្ញាសម្គាល់។

**មាត្រា៩ .-**

ឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ឯកសណ្ឋានគោរមវន្តបុរស**

**ក- អាវ៖**

- អាវធំ កវែងបើក ដៃវែង ពណ៌ខៀវចាស់ ដែលមានលេខកូដ ៨២៨ ប្រើប្រាស់ក្រណាត់រោមចៀម មានឡេវចំនួន២គ្រាប់ មានហោប៉ៅកាត់លើទ្រូងខាងឆ្វេងចំនួន១ និងមានហោប៉ៅមានគម្របសងខាងនៅផ្នែកខាងក្រោម
- នៅចុងដៃអាវទាំងសងខាង មានឡេវចំនួន៤គ្រាប់ ត្រង់ជួរគ្នា។

**ខ- ខោ៖**

- ខោជើងវែងត្រង់ ពណ៌ខៀវចាស់ ដែលមានលេខកូដ ៨២៨
- ដេរផ្នេរបង្កប់ ចង្កេះត ក្បាលខោវែងស្រួចប្រវែង ៥,៥សង់ទីម៉ែត្រ ជីបក្លីខាងមុខម្ខាងមួយ និងមានហោប៉ៅចំនួន៤
- ហោប៉ៅចំហៀង២ មានមាត់បញ្ឆិត
- ហោប៉ៅកាត់ខាងក្រោយ២ នៅសងខាងដេរបង្កប់ មិនមានគម្រប។

**គ- ស្បែកជើង និងស្រោមជើង៖**

- ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ កែងកម្ពស់៣សង់ទីម៉ែត្រឬកែងរាបស្មើ
- ស្រោមជើងពាក់កណ្ដាលស្មងជើង ពណ៌ខ្មៅ។

គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តបុរស ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ។

**២- ឯកសណ្ឋានគោរមវន្តនារី**

**ក- អាវ៖**

- អាវកតាំង បើកចំហមុខបន្តិច ដៃវែង ពណ៌ខៀវចាស់ ប្រើប្រាស់ក្រណាត់ផាមួង ដែលមានក្បាច់ប៉ាក់ផ្កាបង្គុំមួយជុំក មានឡេវបញ្ឆោតចំនួន៥គ្រាប់ពីលើក្បាច់ប៉ាក់បញ្ឈរចំពីមុខ និងមានប្រើខ្សែរូតបង្កប់ពីខាងខ្នង
- នៅលើគល់ស្មាអាវមានប៉ោងបន្តិច និងចុងតួអាវត្រង់ចង្កេះមានរាងប៉ោងក្នុងទម្រង់កន្ទុយប្រា
- នៅចុងដៃអាវទាំងសងខាងមានក្បាច់ប៉ាក់ផ្កាបង្គុំមួយជុំដៃអាវ។

**ខ- សំពត់បត់៖**

- សំពត់បត់ ពណ៌ខៀវចាស់ ប្រើប្រាស់ក្រណាត់ផាមួង និងមានក្បាច់នៅចុងជាយសំពត់ក្នុងទម្រង់ជាផ្កាបង្គុំមួយជុំ
- សម្រុងត្រឹមភ្នែកគោរ។

**គ- ស្បែកជើង និងស្រោមជើង៖**

- ស្បែកជើងកែងចោត កខ្លី ស្បែកពណ៌ខ្មៅ កែងកម្ពស់៥សង់ទីម៉ែត្រឬកែងរាបស្មើ
- ស្រោមជើងកខ្លី ពណ៌ខ្មៅ ។

គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តនារី ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-**

សញ្ញាសម្គាល់គោរមវន្តតាមលំដាប់ថ្នាក់នៃឯកសណ្ឋានផ្លូវការប្រភេទ២ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- សញ្ញាសម្គាល់គោរមវន្តបុរស**

**ក- សញ្ញាសម្គាល់ផ្ទៃខាងក្នុងផ្នែកខាងឆ្វេង**

នៅផ្ទៃខាងក្នុងផ្នែកខាងឆ្វេងនៃតួអាវមានប៉ាក់និមិត្តសញ្ញាសម្គាល់សមាគមឧកញ៉ាកម្ពុជា ទំហំ ៦សង់ទីម៉ែត្រ គុណនឹង ៩សង់ទីម៉ែត្រ និងឈ្មោះរបស់សាមីខ្លួនជាអក្សរឡាតាំង។

**ខ- សញ្ញាសម្គាល់គ្រាប់ឡេវ**

គ្រាប់ឡេវពណ៌ខៀវចាស់ មានរាងជារង្វង់ ដែលមាននិមិត្តសញ្ញាសម្គាល់ពាក្យឧកញ៉ាជាអក្សរឡាតាំងថា OKNHA ផ្នែកខាងលើនៃគ្រាប់ឡេវ និងអក្សរកាត់ជាភាសាអង់គ្លេសថា COA ផ្នែកខាងក្រោមនៃគ្រាប់ឡេវ។

គ្រាប់ឡេវត្រូវបានបែងចែងជា២ខ្នាត ដែលមានទំហំអង្កត់ផ្ចិត ដូចខាងក្រោម៖

- គ្រាប់ឡេវតូច ទំហំ ១,៥សង់ទីម៉ែត្រ កម្រាស់ ០,២សង់ទីម៉ែត្រ សម្រាប់ចុងដៃអាវ បញ្ឈរជាជួរត្រង់គ្នាចំនួន៤គ្រាប់
- គ្រាប់ឡេវធំ ទំហំ ២សង់ទីម៉ែត្រ កម្រាស់ ០,២៥សង់ទីម៉ែត្រ សម្រាប់ឡេវមុខ បញ្ឈរជាជួរត្រង់គ្នាចំនួន២គ្រាប់។

**គ- សញ្ញាសម្គាល់កន្លាស់អាវ**

កន្លាស់អាវជានិមិត្តសញ្ញាសមាគមឧកញ៉ាកម្ពុជា ទំហំ ៣សង់ទីម៉ែត្រ គុណនឹង ៤សង់ទីម៉ែត្រ កម្រាស់ ០,២៥សង់ទីម៉ែត្រ សម្រាប់ខ្ទាស់នៅលើអាវខាងឆ្វេង ធ្វើពីមាស១៨K។

**២- សញ្ញាសម្គាល់គោរមវន្តនារី**

**ក- សញ្ញាសម្គាល់ចុងកអាវ**

សញ្ញាសម្គាល់ចុងកអាវ កតាំង បើកចំហបន្តិច មានក្បាច់ប៉ាក់ផ្កាបង្គុំ កម្ពស់ ៥សង់ទីម៉ែត្រ មួយជុំក។

**ខ- សញ្ញាសម្គាល់ចុងដៃអាវ**

សញ្ញាសម្គាល់ចុងដៃអាវមានក្បាច់ប៉ាក់ផ្កាបង្គុំ កម្ពស់ ៧សង់ទីម៉ែត្រ មួយជុំដៃអាវ។

**គ- សញ្ញាសម្គាល់ក្បាច់ជួរបញ្ឈរចំពីមុខត្រង់កន្លែងដាក់ឡេវ**

សញ្ញាសម្គាល់ត្រង់កន្លែងដាក់ឡេវមានក្បាច់ប៉ាក់បញ្ឈរទម្រង់ផ្កាបង្គុំកម្ពស់ពេញមួយជំហរអាវពីលើដល់ក្រោម។

**ឃ- សញ្ញាសម្គាល់ចុងសំពត់**

សញ្ញាសម្គាល់ចុងសំពត់ មានក្បាច់ប៉ាក់ផ្កាបង្គុំកម្ពស់ ២០សង់ទីម៉ែត្រ មួយជុំសំពត់។

**ង- សញ្ញាសម្គាល់គ្រាប់ឡេវ**

គ្រាប់ឡេវបញ្ចោតពីលើក្បាច់ប៉ាក់បញ្ឈរចំពីមុខ មានរាងជារង្វង់មានស្រៈ( ឳ )ពេញតួនៅចំកណ្តាលទំហំ ១,៥សង់ទីម៉ែត្រ កម្រាស់ ០,១សង់ទីម៉ែត្រ ចំនួន៥គ្រាប់ ដែលមានក្បាលស្រៈជារូបក្បាលហង្សហើយតួស្រៈពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាស។

ច- សញ្ញាសម្គាល់កន្លាស់អាវ

កន្លាស់អាវជានិមិត្តសញ្ញាសមាគមឧកញ៉ាកម្ពុជា ទំហំ ៣សង់ទីម៉ែត្រ គុណនឹង ៤សង់ទីម៉ែត្រ កម្រាស់ ០,២៥សង់ទីម៉ែត្រ សម្រាប់ខ្ទាស់នៅលើអាវខាងឆ្វេង ធ្វើពីមាស១៨K។

គំរូសញ្ញាសម្គាល់នៃឯកសណ្ឋានផ្លូវការប្រភេទ២ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ការគ្រប់គ្រង ការចាត់ចែង និងការប្រើឯកសណ្ឋានផ្លូវការប្រភេទនីមួយៗ របស់គោរមវន្តតាមលំដាប់ថ្នាក់

### មាត្រា១១ .-

ឯកសណ្ឋានផ្លូវការប្រភេទនីមួយៗរបស់គោរមវន្តតាមលំដាប់ថ្នាក់ ត្រូវរៀបចំ ចាត់ចែង បែងចែក និងគ្រប់គ្រងដោយសមាគមឧកញ៉ាកម្ពុជា ដែលជាដៃគូរបស់រាជរដ្ឋាភិបាល ដូចមានកំណត់ក្នុងមាត្រា១៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០២៤/១៣០៩ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ ស្ដីពីគោរមងារឧកញ៉ា។

គោរមវន្តតាមលំដាប់ថ្នាក់គ្រប់រូប ត្រូវដាក់ពាក្យស្នើសុំឯកសណ្ឋានផ្លូវការមកសមាគមឧកញ៉ាកម្ពុជា។

### មាត្រា១២ .-

គោរមវន្តតាមលំដាប់ថ្នាក់ ត្រូវស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទនីមួយៗ ដូចមានកំណត់ខាងក្រោមៈ

១- ឯកសណ្ឋានផ្លូវការប្រភេទ១ ប្រើសម្រាប់គោរមវន្តទាំងអស់ស្លៀកពាក់ក្នុងពេលចូលរួមពិធីបុណ្យជាតិ ពិធីបុណ្យប្រពៃណីជាតិ និងពិធីផ្លូវការផ្សេងៗ។

២- ឯកសណ្ឋានផ្លូវការប្រភេទ២ ប្រើសម្រាប់គោរមវន្តជាសមាជិកសមាគមឧកញ៉ាកម្ពុជា ស្លៀកពាក់ក្នុងពេលចូលរួមពិធីផ្លូវការផ្សេងៗរបស់សមាគមឧកញ៉ាកម្ពុជា។

គោរមវន្តជាសមាជិកសមាគមឧកញ៉ាកម្ពុជា អាចប្រើកន្លាស់អាវនិមិត្តសញ្ញាសមាគមឧកញ៉ាកម្ពុជា ធ្វើពីមាស១៨K ខ្ទាស់នៅលើអាវខាងឆ្វេង នៃឯកសណ្ឋានផ្លូវការប្រភេទ១។

គំរូស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទ១ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យនេះ។

គំរូស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទ២ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៩នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ទណ្ឌកម្ម

### មាត្រា១៣ .-

ជនណាដែលក្លែងឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់ ឬក្លែងបន្លំដោយស្លៀកពាក់ជាសាធារណៈ ដោយគ្មានសិទ្ធិស្លៀកពាក់នូវឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់របស់គោរមវន្ត ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

### មាត្រា១៤ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦

ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្តបុរស



អាវពីមុខ



អាវពីក្រោយ



ខោពីមុខ



ខោពីក្រោយ



ស្រោមជើង



ស្បែកជើង

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦
ស្ដីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ១របស់គោរមវន្តនារី



អាវពីមុខ



អាវពីក្រោយ



ស្រោមជើង



សំពត់ពីមុខ



សំពត់ពីក្រោយ



ស្បែកជើង

ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦

ស្ដីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## គំរូសញ្ញាសក្តិគោរមវន្តតាមលំដាប់ថ្នាក់សម្រាប់ពាក់លើស្មាទាំងសងខាងនៃឯកសណ្ឋានផ្លូវការប្រភេទ១




លោកអ្នកឧកញ៉ា




អ្នកឧកញ៉ា




ឧកញ៉ា

ឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៦

ស្ដីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## គំរូសញ្ញាសម្គាល់គោរមវន្តតាមលំដាប់ថ្នាក់នៃឯកសណ្ឋានផ្លូវការប្រភេទ១




សញ្ញាសម្គាល់ចុងកអាវ




គ្រាប់ឡេវធំ




គ្រាប់ឡេវតូច

ឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៦
ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តបុរស



អាវពីមុខ



អាវពីក្រោយ



ផ្ទៃខាងក្នុងផ្នែកខាងឆ្វេង



ខោពីមុខ



ខោពីក្រោយ



ស្រោមជើង



ស្បែកជើង

ឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦

ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

# គំរូឯកសណ្ឋាននៃឯកសណ្ឋានផ្លូវការប្រភេទ២របស់គោរមវន្តនារី



អាវពីមុខ



អាវពីក្រោយ



ស្រោមជើង



សំពត់ពីមុខ



សំពត់ពីក្រោយ



ស្បែកជើង

ឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦

ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

## គំរូសញ្ញាសម្គាល់នៃឯកសណ្ឋានផ្លូវការប្រភេទ២

### ១.សញ្ញាសម្គាល់គោរមវន្តបុរស



ផ្ទៃខាងក្នុងផ្នែកខាងឆ្វេង



គ្រាប់ឡេវតូច



គ្រាប់ឡេវធំ



សញ្ញាសម្គាល់កន្លាស់អាវ

### ២.សញ្ញាសម្គាល់គោរមវន្តនារី


គំរូក្បាច់



គ្រាប់ឡេវតូច



សញ្ញាសម្គាល់កន្លាស់អាវ


ក្បាច់ចុងកអាវ


ក្បាច់ប៉ាក់បញ្ឈរចំពីមុខ


ក្បាច់ចុងដៃអាវ


ក្បាច់ចុងសំពត់

ឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦

ស្ដីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទ១**

**១.គោរមវន្តបុរស**



លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា

## ២.គោរមវន្តនារី



លោកអ្នកឧកញ៉ា



អ្នកឧកញ៉ា



ឧកញ៉ា

ឧបសម្ព័ន្ធទី៩នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦

ស្តីពីឯកសណ្ឋានផ្លូវការរបស់គោរមវន្តតាមលំដាប់ថ្នាក់

**គំរូស្លៀកពាក់ឯកសណ្ឋានផ្លូវការប្រភេទ២**



គោរមវន្តបុរស



គោរមវន្តនារី